# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧១ អនក្រ.បក

# អនុក្រឹត្យ
ស្តីពី
## ការកែប្រែតំបន់ការពារទេសភាពអន្លង់ព្រីង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្ដល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការបង្កើតតំបន់ការពារទេសភាពអន្លង់ព្រីង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកែប្រែតំបន់ការពារទេសភាពអន្លង់ព្រីង ពីផ្ទៃដីទំហំ២១៧(ពីររយដប់ប្រាំពីរ)ហិកតា មកផ្ទៃដីទំហំ២១៩(ពីររយដប់ប្រាំបួន)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពត ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា(តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984)ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានគោលបំណងដូចតទៅ៖

- ធានាការថែរក្សានិងការពារសោភណភាពធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងសារព័នមជ្ឈដ្ឋានធម្មជាតិ សម្រាប់គោលដៅកម្សាន្តនិងទេសចរណ៍
- ថែរក្សាការពារ វប្បធម៌ ប្រពៃណី ការអភិវឌ្ឍ និងសារៈសំខាន់ផ្នែកវប្បធម៌របស់សហគមន៍មូលដ្ឋាន
- រក្សាលំនឹងបរិស្ថាន និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ផ្ដល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់ការពារទេសភាពអន្លង់ព្រីង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តកំពត ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ .-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី មានជាអាទិ៍ ដីលំនៅឋាន ដីស្រែចម្ការ ដីអាស្រ័យផលស្របច្បាប់របស់ប្រជាពលរដ្ឋ ដែលអនុលោមតាមអនុក្រឹត្យស្ដីពីការបង្កើតតំបន់ការពារទេសភាពអន្លង់ព្រីង ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

ផែនទីតំបន់ការពារទេសភាពអន្លង់ព្រីង ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពត



**ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣**

**ចំណុចនិយាមកានៃផែនទីតំបន់ការពារទេសភាពអន្លង់ព្រីង**

| ID | X | Y |
|---|---|---|
| 1 | 448537 | 1159351 |
| 2 | 448735 | 1159127 |
| 3 | 448582 | 1158808 |
| 4 | 448464 | 1158510 |
| 5 | 448447 | 1158304 |
| 6 | 448570 | 1158288 |
| 7 | 448537 | 1158083 |
| 8 | 448467 | 1157848 |
| 9 | 448519 | 1157780 |
| 10 | 448395 | 1157663 |
| 11 | 448232 | 1157729 |
| 12 | 448187 | 1157531 |
| 13 | 448328 | 1157369 |
| 14 | 448443 | 1157313 |
| 15 | 448503 | 1157324 |
| 16 | 448590 | 1157424 |
| 17 | 448510 | 1157554 |
| 18 | 448433 | 1157644 |
| 19 | 448543 | 1157748 |
| 20 | 448748 | 1157465 |
| 21 | 448988 | 1156983 |
| 22 | 448873 | 1157220 |
| 23 | 449213 | 1156915 |
| 24 | 449371 | 1156695 |
| 25 | 449503 | 1156361 |
| 26 | 449385 | 1156197 |
| 27 | 449239 | 1156056 |
| 28 | 449111 | 1155939 |
| 29 | 449071 | 1155815 |
| 30 | 449010 | 1155882 |
| 31 | 448978 | 1155963 |
| 32 | 448962 | 1156122 |
| 33 | 448826 | 1156143 |
| 34 | 448885 | 1156375 |
| 35 | 448861 | 1156736 |
| 36 | 448424 | 1156844 |
| 37 | 448170 | 1156956 |
| 38 | 447964 | 1157072 |
| 39 | 447757 | 1157164 |
| 40 | 447661 | 1157345 |
| 41 | 447726 | 1157644 |
| 42 | 447799 | 1157875 |
| 43 | 447877 | 1158099 |
| 44 | 447880 | 1158315 |
| 45 | 447825 | 1158458 |
| 46 | 447623 | 1158518 |
| 47 | 447570 | 1158695 |
| 48 | 447696 | 1158682 |
| 49 | 447785 | 1158528 |
| 50 | 447956 | 1158499 |
| 51 | 448018 | 1158727 |
| 52 | 448144 | 1158982 |
| 53 | 448355 | 1159196 |